ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៤៨

ចុះថ្ងៃទី២២-៨-២០០១

សាលដីកា

លេខ : ០៣

ចុះថ្ងៃទី០២-០១-២០០២

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បាន បើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែមករា ឆ្នាំ២០០២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | ឃឹម | ប៉ុណ្ណ | ប្រធាន |
| ២- លោក | ឃឹម | ស៊ីផល | ចៅក្រម |
| ៣- លោក | ជីវ | កេង | ចៅក្រម |
| ៤- លោក | ប្រាក់ | គឹមសាន | ចៅក្រម |
| ៥- លោក | សោម | សិរីវឌ្ឍ | ចៅក្រមរបាយការណ៍ |
| លោក | សុខ | ប៊ុនលង | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| លោក | ណាយ | សារី | ព្រះរាជអាជ្ញា |

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលេខ ១៣ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី២១ ខែ មិនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៤៨ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០១ របស់ តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ ទូច សាខន "ចុងបណ្តឹងសាទុក្ខ" ភេទ ប្រុស អាយុ៤០ ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិក ក្រសួងការបរទេស ទីលំនៅមុនពេលចាប់ខ្លួន ភូមិ ឃុំ ឈើទាល ស្រុកកៀនស្វាយ ខេត្ត កណ្តាល ឪពុកឈ្មោះដួង ងិម "ស" ម្តាយឈ្មោះអ៊ិច ទេន "ស" ទោសពីមុនគ្មាន ។

ត្រូវ ចោទពីបទ : មនុស្សឃាតដោយចេតនានិងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ.ឃុំ ឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី០៥-០៨-៩៩ ។

- មេធាវី លោក ពេជ រិណាល

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គឹម ចា ភេទប្រុស អាយុ២៨ ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិ ឃុំ ឈើទាល ស្រុកកៀនស្វាយ ខេត្ត កណ្តាល ។

- មេធាវី គ្មាន

- តាមពាក្យបណ្ដឹងចុះថ្ងៃទី៣-០៨-៩៩ របស់ឈ្មោះគីម ថា អ៊ុយ ពៀង , អ៊ុយ ស៊ិន គីម មឿន គីម ថននិងលៀង យ៉ាន់ ថា៖ នៅយប់ថ្ងៃទី៤-០៨-៩៩ វេលាម៉ោង៧និង៣០នាទី នាងឈ្មោះ សេង រិទ្ធី បានចុះមកក្រោមផ្ទះចូលក្នុងបង្គន់ ពេលនោះឈ្មោះទូច សាខន បានបាញ់សំលាប់នាង សេង រិទ្ធី នៅក្នុងបង្គន់នោះតែម្ដង ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការខេត្ត កណ្ដាល ថា៖ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះទូច សាខន អាយុ៤៨ ឆ្នាំ ពីបទមនុស្សឃាតដោយចេតនានិងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ.ឃុំ ជើងទាល ស្រុកគៀនស្វាយខេត្ត កណ្ដាល កាលពីថ្ងៃ ០៤-០៨-៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្ដន្ទាទោសតាមមាត្រា ៤៤និងច្បាប់ ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ០៣ "ក "ចុះថ្ងៃទី២៥-០១-២០០០ របស់តុលាការខេត្ត កណ្ដាល ដែលមានសេចក្ដីសំរេចដូចតទៅ ៖

១ - ផ្ដន្ទាទោសឈ្មោះទូច សាខន ដាក់ពន្ធនាគារកំណត់១៦ឆ្នាំ៦ខែ គិតពីថ្ងៃចាប់ខ្លួនបានថ្ងៃទី០៥-៨-១៩៩៩ ពីបទ៖មនុស្សឃាតចេតនានិងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិ.ឃុំ ជើងទាល ស្រុកគៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី០៥-០៨-៩៩ បទល្មើសព្រហ្មទណ្ឌដែលចែងនិងផ្ដន្ទាទោសតាមមាត្រា ៣២ និង៤៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - វត្ថុតាងមាន៖ កាំភ្លើងខ្លីអា៥៩ លេខ៨៥៣៧៨.១ដើម បង់ប្រកគ្រាប់ចំនួន០១ គ្រាប់កាំភ្លើង០១គ្រាប់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ សារុងចំនួន០១ ពណ៌បៃតង អាវយឺតដៃខ្លីរូបក្រពី ពណ៌ផ្ទៃមេឃចំនួន០១ ត្រូវរឹបអូសរួចបំផ្លាញចោល ។

៣ - សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទនិងតំណាងជនរងគ្រោះ ។ បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០៨ ចុះថ្ងៃទី០៩-០២-២០០០ របស់ឈ្មោះទូចសាខន តវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ០៣ "ក "ចុះថ្ងៃទី២៥-០១-២០០០ របស់តុលាការខេត្ត កណ្ដាល លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា៖សូមក្រុមប្រឹក្សាសម្រេចថា តវ៉ាបៀបអង្គុតពីយាម ដែលប្រឆ្បាកំសោរង ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៧៨ ចុះថ្ងៃទី២១-០៣-២០០១ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ ៖

១ - ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៩-០២-២០០០ របស់ឈ្មោះទូច សាខន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២ - បដិសេធសាលក្រមលេខ០៣ "ក "ចុះថ្ងៃទី២៥-០១-២០០០ របស់តុលាការខេត្តកណ្ដាល ចោលជាអាសារបង់ ។

៣ - សម្រេចឱ្យឈ្មោះទូច សាខន រួចខ្លួនពីបទចោទក្នុងបទ៖ ធ្វើមនុស្សឃាតដោ

ដោយចេតនា និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅថ្ងៃទី០៥-០៨-៩៩ ស្ថិតនៅភូមិ.ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្ត កណ្ដាល ។

បង្គាប់ឱ្យដោះលែងឈ្មោះទូច សាខន ដោយមានសេរីភាពឡើងវិញ បើគ្មានដីកាឃុំខ្លួន ពីបទល្មើសផ្សេងទៀត ។

៤- សាលដីកានេះជំនុំជំរះនៅថ្ងៃទី ១៦-៣-២០០២ ចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណីនិងជនជាប់ចោទ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០០២ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី ៤ - ០៣ - ២០០២ របស់អគ្គព្រះរាជអាជ្ញារង សាលាឧទ្ធរណ៍ តវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ៣៨ ចុះថ្ងៃទី២៦ - ០៣ - ២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី២៨ - ០៦ - ២០០២ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

- បានឃើញសារណាតបចុះថ្ងៃទី ១៨ - ១០ - ២០០២ របស់ជនជាប់ចោទឈ្មោះ ទូច សាខន ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះទូច សាខន ពីបទមនុស្សឃាតដោយចេតនានិងប្រើប្រាស់អាវុធខុសច្បាប់ ។

- ទុកជាមោឃៈ លើសាលដីការបស់សាលាឧទ្ធរណ៍ .

- បានស្ដាប់សារណារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

- បានស្ដាប់សារណាតបរបស់ជនជាប់ចោទឈ្មោះទូច សាខន .

- បានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះគីម ថា បានឆ្លើយនាពេលសវនាការថា : នៅពេលកើតហេតុ គឺមិនច្បាស់លាស់ទេ មិនដឹងនរណាទេ ។ សូមតុលាការដោះលែងគាត់ឱ្យមានសេរីភាពឡើងវិញ ដើម្បីឱ្យគាត់ទៅធ្វើការវិញចុះ ។

- បានស្ដាប់លោកពេជ វិសាល ជាមេធាវីការពារជនជាប់ចោទធ្វើសេចក្ដីសន្និដ្ឋាននាពេលសវនាការថា : ក្នុងរឿងនេះ ចំពោះការចោទប្រកាន់របស់ព្រះរាជអាជ្ញារបស់តុលាការខេត្ត កណ្ដាល ទកលើកូនក្ដីខ្ញុំ ពុំមានភស្តុតាងច្បាស់លាស់ទេ ជនរងគ្រោះនិងជនជាប់ចោទជាគូសត្រូវនឹងគ្នា ចំរុងនឹងវេប្រការ ។ ជនជាប់ចោទមិនចេះប្រើកាំភ្លើងទេ ។ មានសាក្សីឃើញថាមុនពេលកើតហេតុមានជនសង្ស័យ០៥នាក់ជិះម៉ូតូរត់គេចពីកាត់ខុងផ្ទះជនរងគ្រោះ ។ អាវកូនក្ដីខ្ញុំប្រឡាក់ជ័រដើមអំពិលទុំទាំង មិនមែនប្រឡាក់ឈាមទេ ។ បទល្មើសមិនមែនបទល្មើសជាក់ស្ដែង ទាំងរបាយការណ៍នគរបាល ទាំងសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា បង្ហាញការ

សង្ស័យ ។ ក្នុងទិដ្ឋភាពដែលត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ តាមមាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញ ។ ដូច្នេះសូមតុលាការ តម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានពីមុនដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ.

- ក្រោយពីបានស្តាប់ សារណា របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍. សារណារបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៣ចុះថ្ងៃទី២១-០៣-២០០១ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានដោយយោងតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទ គឺជាការពុំត្រឹមត្រូវទេពីព្រោះពុំទាន់បានស៊ើបអង្កេតឱ្យបានត្រឹមត្រូវលើចំណុចដែលអគ្គព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការទេ។ដូច្នេះចំណុច៣ មាត្រា២០៥ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ សាលដីកាព្រហ្មទណ្ឌនេះត្រូវទុកជាមោឃៈ ។

- យល់ឃើញថា ក្រោយពេលកើតហេតុភ្លាម សាក្សីបានឃើញជនជាប់ចោទតែម្នាក់គត់ដែលមានកាន់កាំភ្លើងនៅដៃ ដោយមានស្រោមដៃមួយនៅក្នុងទឹក ហើយពុំទាន់មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា មានជនម្នាក់ទៀតដែលជាឃាតករ បាញ់សម្លាប់ជនរងគ្រោះទេ ។

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណា ជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី២១-០៣-២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីកំបាំងមុខ

ជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខ ១៣ ចុះថ្ងៃទី២១ - ០៣ - ២០០១ របស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

២ - ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ ៣៨ ចុះថ្ងៃទី២១ - ០៣ - ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨ ចុះថ្ងៃទី ២២ - ០៨ - ២០០១ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០២ ។